#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូក៦៖

# ការចូលរួមជាសាធារណៈ

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

# ជំពូក៦៖ ការចូលរួមជាសាធារណៈ

## ៦.១ សេចក្តីផ្តើម

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន-សង្គមពេញលេញ តម្រូវឱ្យមានការចូលរួមជាសាធារណៈ ដែលជាផ្នែកមួយដ៏សំខាន់ដើម្បីឱ្យមានភាពត្រឹមត្រូវ និងអាចទទួលយកបាន។ ការសិក្សានេះ **ក្រុមហ៊ុន គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ** (Creative Green Design Co., Ltd)បានចុះធ្វើការសម្ភាសន៍ជាមួយក្រសួងមន្ទីរ/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន ម្ចាស់គម្រោង និងប្រជាជនជុំវិញតំបន់គម្រោងអភិវឌ្ឍន៍ ដែលមានទីតាំងស្ថិតក្នុងខេត្តព្រះសីហនុ។ ការសម្ភាសន៍ និងពិគ្រោះយោបល់នេះ ក្នុងគោលបំណងដើម្បីទទួលបាននូវការចូលរួមជាសំណួរ សំណូមពរ និងអនុសាសន៍ផ្សេងៗ ក្នុងការជួយកែលម្អដើម្បីបញ្ចៀស និងកាត់បន្ថយផលប៉ះពាល់ពីគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចនេះ ឱ្យនៅកំរិតអប្បបរមា និងអាចទទួលយកបាន។

ការចូលរួមជាសាធារណៈត្រូវបានធ្វើឡើង ដើម្បីឱ្យសាធារណៈជនពាក់ព័ន្ធបានដឹងឮថាមានក្រុមហ៊ុនTELCOTECH, Ltd បានមកវិនិយោគលើ គម្រោងខ្សែកាប្លិ៍អុបទិចបង្កប់ក្រោមបាតសមុទ្រដែលបានរត់ចេញពីប្រទេសម៉ាឡេស៊ីឆ្លងកាត់ឈូងសមុទ្រថៃចូលមកប្រទេសកម្ពុជាដែលនៅក្នុងតំបន់របស់ពួកគាត់អាស្រ័យផលនេសាទ។ ម៉្យាងវិញទៀត ការចូលរួមជាសាធារណៈនេះ តម្រូវឲ្យអ្នកពាក់ព័ន្ធទាំងឡាយធ្វើការផ្តល់មតិយោបល់សម្រាប់កែលម្អ ផ្តល់សំណូមពរ និងស្តាបនាក្នុងការជួយសម្រួលដល់ការអនុវត្តគម្រោងឲ្យបានល្អប្រសើរ មានភាពរលូន និងមានប្រសិទ្ធិភាពឲ្យស្របទៅតាមបរិបទនៃការអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព។

ការចូលរួមជាសាធារណៈ ត្រូវការជាចាំបាច់សម្រាប់ធ្វើការវាយតំលៃលើហេតុប៉ះពាល់វិជ្ជមាន និងអវិជ្ជមាន ដែលមានឥទ្ធិពលលើកត្តាសេដ្ឋកិច្ចសង្គម បរិស្ថានធម្មជាតិ សហគមន៍ទាំងមូលដ្ឋានតាមរយៈគម្រោងអភិវឌ្ឍន៍របស់ក្រុមហ៊ុន។ ដូច្នេះទាមទារឲ្យមានការចូលរួមជាសាធារណៈ ដែលផ្តោតសំខាន់លើការចុះផ្សាយ ស្ទាបស្ទង់មតិ ការជួបពិភាក្សាជាមួយ មន្ទីរ/ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋដែលរស់នៅក្នុង និងជុំវិញតំបន់គម្រោង ដើម្បីទទួលបាននូវគំនិតរិះគន់ យោបល់គាំទ្រ ព័ត៌មានលម្អិតពាក់ព័ន្ធនឹងបរិស្ថានដែលមានស្រាប់ និងអនុសាសន៍នានា ដែលអាចជាប្រភពទិន្នន័យមួយដ៏សំខាន់ក្នុងការសម្រេចចិត្ត។

## ៦.២ ការពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុជាមួយអាជ្ញាធរ និងមន្ទីរដែលពាក់ព័ន្ធ

ការពិគ្រោះយោបល់ ត្រូវបានធ្វើឡើងដោយការប្រជុំពិភាក្សាដែលមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន មន្ទីរ/ស្ថាប័ន និងអង្គការដែលពាក់ព័ន្ធជាច្រើន។ ការប្រជុំនេះត្រូវបានធ្វើនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៥ វេលាម៉ោង០៨:៣០នាទីព្រឹក នៅសាលាខេត្តព្រះសីហនុក្រោមអធិបតីភាពរបស់ **ឯកឧត្តម ឈិន សេងងួន** អភិបាលរងខេត្តព្រះសីហនុ និងមាន **កញ្ញា ឌុច សុធាវីន** តំណាងឲ្យក្រុមហ៊ុន **គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ** ជាអ្នកធ្វើបទបង្ហាញស្តីពី ការរៀបចំរបាយការណ៍សិក្សាវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ នៃគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចក្រោមបាតសមុទ្រកម្ពុជា។ ការប្រជុំពិភាក្សានេះមានមតិយោបល់ និងអនុសាសន៍ដូចមានរៀបរាប់ខាងក្រោម៖

រូបភាព៦.១៖កិច្ចប្រជុំពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ



(ប្រភព៖ Creative Green Design Co.,Ltd ២០១៥)

Draft

### ៦.២.១ ការបញ្ចេញមតិយោបល់របស់ឯកឧត្តម ឈិន សេង ងួន

**ឯកឧត្តម ឈិន សេង ងួន** អភិបាលរងខេត្តព្រះសីហនុ មានចំណាប់អារម្មណ៍ និងមតិយោបល់ជុំវិញគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចក្រោមបាតសមុទ្រកម្ពុជាដូចខាងក្រោម៖

- ឯកឧត្តមបានលើកជាសំណួរថា តើខ្សែកាប្លិ៍ដែលរត់កាត់ដែនទឹកសមុទ្រខេត្តព្រះសីហនុមានប៉ុន្មានគីឡូម៉ែត្រ? ហើយត្រូវមានផែនទីសម្រាប់បង្ហាញផង ដោយមានភ្ជាប់និយាមការ អោយបានច្បាស់ និងត្រូវមានអ្វីជាសម្អាងបញ្ជាក់។ ដូច្នេះទើបខាងរដ្ឋបាលជលផល អាចយកទិន្នន័យទាំងនេះមកពិនិត្យ និងផ្ទៀងផ្ទាត់មើលថា តើខ្សែកាប្លិ៍នេះរត់កាត់ដែនអភិរក្សណាខ្លះ ឬប្លង់នេះពិតជាបានជៀសផុតពីតំបន់អភិរក្សផ្កាថ្មដែរឬទេ ដោយសារខាងរដ្ឋបាលជលផលកំពុងតែពង្រីកដែនអភិរក្សធនធានបាតសមុទ្ររបស់ខ្លួន ដូចជាតំបន់ផ្កាថ្ម ស្មៅសមុទ្រ កន្លែងមេពូជជាដើម ដោយមិនចង់សូម្បីតែអនុញ្ញាតឱ្យអ្នកមុជទឹក ទៅមើលផង។
- ឯកឧត្តម ក៏មានប្រសាសន៍បន្ថែមថា ពេលផែនទីបានធ្វើរួចហើយត្រូវ ឆ្លងកាត់ការពិនិត្យពីខាងរដ្ឋបាលជលផលខេត្ត ក្រសួង សហគមន៍អភិរក្សធនធានសមុទ្រ និងអង្គការអភិរក្សដែលមានអ្នកជំនាញបរទេសខាងមុជទឹកជាដើម។
- ឯកឧត្តម បានបញ្ជាក់ផងដែរថា រដ្ឋាភិបាលកំពុងដាក់ឆ្នេរអូត្រេះជាឆ្នេរគំរូ ដោយស្ថិតក្រោមការគ្រប់គ្រងរបស់ គណៈកម្មការគ្រប់គ្រងតំបន់ឆ្នេរ និងក្រសួងទេសចរណ៍ ហើយឆ្នេរនេះក៏ត្រូវធ្វើសួនផង ដូច្នេះ ឯកឧត្តមបារម្ភពីការត្រួតស៊ីគ្នារវាង ខ្សែកាប្លិ៍ និងការធ្វើសួន ថាតើមួយណាត្រូវធ្វើមុន ហើយខ្សែកាប្លិ៍ត្រូវកប់ជម្រៅប៉ុន្មាន ដើម្បីជៀសវាងការជីកប៉ះខ្សែកាប្លិ៍ និងការសាងសង់រួចត្រូវជីកកកាយឡើងវិញជាដើម។
- បន្ថែមពីនេះ ឯកឧត្តមក៏បានបន្តទៀតថា ការសាងសង់នេះបានដឹងឮពីមន្ទីរដែនដី មន្ទីរសាធារណៈការ និងប្រៃសនីយ៍ដែរឬទេ ហើយបានចុះក្នុងប្លង់គោលរបស់មន្ទីរឬនៅ ដោយសារខាងមន្ទីរដែនដីមានប្លង់មេ តំបន់ការពារ និងតំបន់អភិវឌ្ឍន៍ជាដើម សម្រាប់រៀបចំដែនដីទាំងមូល។ ហើយទីតាំងសាងសង់ស្ថានីយ៍ជារបស់អ្នកណា នឹងបានដឹងលឺពីមន្ទីរដែនដីឬនៅ?
- ឯកឧត្តមចង់អោយក្រុមហ៊ុនពេលសាងសង់រួច ត្រូវមានប្លង់ខ្សែកាប្លិ៍បញ្ជាក់ពីការរត់ពីណាទៅណា និងកប់ក្នុងជម្រៅប៉ុន្មាន អោយបានច្បាស់សម្រាប់តំកល់នៅខេត្ត។
- ឯកឧត្តម ក៏បានលើកជាសំនួរពីបញ្ហាផលប្រយោជន៍សេដ្ឋកិច្ចថា តើប្រទេសជាតិទទួលបានផលប្រយោជន៍អ្វីខ្លះ ហើយប្រជាជនក្នុង និងក្បែរតំបន់គម្រោងទទួលបានប្រយោជន៍អ្វីខ្លះ?

- ឯកឧត្តម នៅតែបារម្ភ ពីរបាយការណ៍ និងឯកសារផ្សេងៗនៅមិនទាន់មាន ប្រភពច្បាស់លាស់ និងមានអ្វីជាសម្អាងថាលទ្ធផលសិក្សាក៏ដូចជាឯកសារផ្សេងៗ ដែលយកមកបង្ហាញគឺត្រឹមត្រូវ ចំពោះបញ្ហា មេពូជត្រី ពេលខ្សែកាប្លិ៍កប់អាចចំកន្លែងមេពូជនៅ ហើយប្រេកង់ខ្សែកាប្លិ៍ក៏អាចប៉ះពាល់ដល់ការបន្តពូជរបស់ត្រីដែរ ដូច្នេះក្រុមហ៊ុនត្រូវសិក្សាអោយបានច្បាស់។

ជាកិច្ចបញ្ចប់ **ឯកឧត្តម ឈិន សេខ ខួន** ធ្វើការបូកសរុបសេចក្តីក្នុងកិច្ចប្រជុំថ្ងៃនេះ រួមមាន៩ចំនុច ដែលក្រុមហ៊ុនត្រូវយកទៅពិចារណា ដូចជាៈ

1. ក្រុមហ៊ុនត្រូវបង្ហាញអោយច្បាស់ពីគន្លងកប់ខ្សែកាប្លិ៍ទាំងក្នុងទឹក និងលើគោកដែលមាននិយាមការ ច្បាស់លាស់ ដើម្បីតំកល់ប្លង់នៅសាលាខេត្ត។
2. ការអូសខ្សែកាប្លិ៍គួរបង្វែរទៅតាមព្រែកវិញ កុំអូសកាត់សួនច្បារ ផ្នូរកំសាន្ត កន្លែងងូតទឹករបស់ប្រជាពលរដ្ឋ។
3. ការសិក្សាបាតសមុទ្រគួរមាន video clip ទុកមើល និងមានឯកសារឱ្យរឹងមាំ សម្រាប់ជាភ័ស្តុតាងបង្ហាញ។
4. ចំពោះក្រុមមុជទឹកស្រាវជ្រាវបាតសមុទ្រ មានការទទួលស្គាល់ពីស្ថាប័នណា ឈ្មោះអ្វី។
5. ក្រុមមុជទឹកត្រូវតែមានការពិគ្រោះយោបល់ជាមួយអង្គការ ឬភ្នាក់ងារដែលកំពុងប្រតិបត្តិការក្នុងខេត្តព្រះសីហនុ ទាក់ទងនឹងការអភិរក្សធនធានបាតសមុទ្រ ដោយសារមានតែពួកគាត់ ខាងជលផលទេដែលដឹងពីវិសាលភាពនៃធនធានបាតសមុទ្រ ផ្នែកណាខ្លាំង និងផ្នែកណាកំពុងឈានទៅរកមហន្តរាយ និងការធ្វើអោយមានការកកើតឡើងវិញ។
6. ការតបណ្តាញ គួរតែធ្វើនៅរដូវដែលមានភ្ញៀវទេសចរតិច។
7. ការអូសខ្សែកាប្លិ៍នេះមានផលប្រយោជន៍អ្វីខ្លះដល់ ប្រទេសជាតិ និងប្រជាពលរដ្ឋ? ត្រូវបកស្រាយពីផលប្រយោជន៍ឱ្យបានច្បាស់ និងត្រូវមានវិធានការកាត់បន្ថយផលប៉ះពាល់បែបណា ដើម្បីឱ្យប្រជាជនក្នុងតំបន់មានទំនុកចិត្ត។
8. ក្រុមហ៊ុនគួរតែមានការផ្សព្វផ្សាយ គម្រោងឲ្យសាធារណៈជនបានដឹងលឺ។

រូបភាព៦.២៖ ឯកឧត្តម ឈិន សេង ងួន ក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ



(ប្រភព៖ Creative Green Design Co., Ltd ២០១៥)

Draft

៦.២.២ ការបញ្ចេញមតិយោបល់ របស់តំណាងក្រុមហ៊ុន Telcotech., Ltd

**លោក ឡេ ហុកលាន** តំណាងក្រុមហ៊ុនតែលកូថេក មានចំណាប់អារម្មណ៍ និងមតិយោបល់ជុំវិញគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍ដូចខាងក្រោម៖

- ឆ្លើយតបទៅនឹងសំណួរទីតាំងសាងសង់ ខាងក្រុមហ៊ុនបានទាក់ទងទៅខាងមន្ទីរដែនដី នគររូបនីយកម្ម រួចហើយ។
- ចំពោះប្លង់អូរជីកចេញពីស្ថានីយទៅមាត់សមុទ្របានការអនុញ្ញាតពីខេត្ត និងក្រសួងសាធារណៈការដឹងឮ។

- មួយវិញទៀត ចំពោះនិយាមការរបស់ខ្សែកាប្លិ៍កប់នៅបាតសមុទ្រ ខាងក្រុមហ៊ុនមានជាគម្រោងបឋមសម្រាប់ធ្វើការសិក្សាផ្ទាល់លើសមុទ្រ បន្ទាប់ពីសិក្សាចប់ទើបក្រុមហ៊ុនចេញជាលទ្ធផលកូរអរដោនេពិតប្រាកដមួយ សម្រាប់ប្រគល់ទៅក្រសួងពាក់ព័ន្ធ។
- ចំពោះបញ្ហាសាងសង់សូនគំរូ ក្រុមហ៊ុនបានស្នើសុំប្លង់គំរូសាងសង់សូនសម្រាប់យកទៅសិក្សាបន្ថែមទៀត ដើម្បីប្រៀបធៀប និងកែសំរួល។ ដោយលោកបានបញ្ជាក់ថា តាមបច្ចេកទេសរបស់ក្រុមហ៊ុន ការកប់ខ្សែកាប្លិ៍ពីមាត់ឆ្នេរមកស្ថានីយ៍គឺកប់ក្នុងជម្រៅ ១,២ម៉ែត្រ ពីមាត់ទឹកទៅជម្រៅទឹក១៥ម៉ែត្រ គឺកប់៣ម៉ែត្រទៅក្នុងបាតសមុទ្រ ហើយជម្រៅទឹកពី១៥ម៉ែត្រឡើងទៅគឺកប់ ១,៥ម៉ែត្រទៅក្នុងបាតសមុទ្រ ម្យ៉ាងវិញទៀត ក្នុងជម្រៅទឹកចាប់ពី១គីឡូម៉ែត្រឡើងទៅគឺគេមិនកប់ទេ លើកលែងតែឈូងសមុទ្រថៃ ដែលមានជម្រៅត្រឹមតែ១០០ម៉ែត្រ។
- ក្រុមហ៊ុនបានជួប និងជូនឯកសារផ្សេងៗទៅរដ្ឋបាលជលផលនៅភ្នំពេញរួចហើយ។

រូបភាព៦.៣៖ លោក ឡេ ហុកលាន ក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ



(ប្រភព៖ Creative Green Design Co., Ltd ២០១៥)

### ៦.២.៣ ការបញ្ចេញមតិយោបល់របស់មន្ទីរបរិស្ថានខេត្តព្រះសីហនុ

**លោក សាមុត សុធារិទ្ធ** ប្រធានមន្ទីរបរិស្ថានខេត្តព្រះសីហនុ មានចំណាប់អារម្មណ៍ និងមតិយោបល់ជុំវិញគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍ដូចខាងក្រោមៈ

- ទាក់ទងនឹងការអូសបណ្តាញខ្សែកាប្លិ៍ ពីផ្ទៃសមុទ្ររហូតមកដីឆ្នេរ លោកសំណូមពរ អោយក្រុមហ៊ុនរៀបចំឱ្យបានច្បាស់ ពាក់ព័ន្ធនឹងការចាប់ផ្តើមដំណើរការរៀបចំ និងតបណ្តាញ មានន័យថាក្រុមហ៊ុនគួរមានលេខ GPS នៃគន្លងខ្សែតាមបាតសមុទ្រ សិក្សាពីផលប៉ះពាល់ឱ្យបានច្បាស់ គួរមានរូបភាព វីដេអូពីសកម្មភាព និងប្រភពចេញពីស្ថាប័នណាព្រមទាំងឯកសារសិក្សាផ្សេងៗទទួលស្គាល់ដោយស្ថាប័នណាខ្លះ។
- លោកក៏មានយោបល់បន្ថែមថា ការអូសបណ្តាញខ្សែកាប្លិ៍ ពីឆ្នេរមកស្ថានីយ៍ គួរតែបញ្ចៀសពីឆ្នេរដោយតទៅតាមអូរ រួចចូលទៅស្ថានីយ៍វិញ។ ដោយលោកបារម្ភ ថ្ងៃក្រោយពេលតំបន់ឆ្នេរមានការអភិវឌ្ឍកាន់ខ្លាំងទៅអាចមានបញ្ហា ការកាយការជីកឡើងវិញ។

រូបភាព៦.៤៖ លោក សាមុត សុធារិទ្ធ កិច្ចប្រជុំពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ



(ប្រភព៖ Creative Green Design Co., Ltd ២០១៥)

Draft

៦.២.៤ ការបញ្ចេញមតិយោបល់របស់អង្គការ CNRO

**លោក សុខ សុខុម** ប្រធានអង្គការ CNRO មានចំណាប់អារម្មណ៍ និងមតិយោបល់ជុំវិញគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍ដូចខាងក្រោមៈ

- លោកបានលើកឡើងថា តំបន់ឆ្នេរអូរត្រេះបានចាត់ចូលជា ឆ្នេរស្អាតបំផុតលើពិភពលោក ដូចនេះគម្រោងសាងសង់ខ្សែកាប្លិ៍គួរតែអាចបញ្ចៀសពីឆ្នេរនេះបានដែរឬទេ?
- លោកក៏បានសង្កត់ធ្ងន់ថា ការសិក្សាគួតែធ្វើឡើងអោយបានស៊ីជម្រៅជៀសវាងពេលមានផលប៉ះពាល់កើតឡើង តើអ្នកណាទទួលខុសត្រូវ ដោយលោកបញ្ជាក់ថា លោកក៏មិនដឹងស៊ីជម្រៅដែរថា ខ្សែកាប្លិ៍នេះនឹងប៉ះពាល់ដល់វិទ្យុសកម្មមេកានិកក្នុងតំបន់ ឬប៉ះពាល់ដល់អ្នកនេសាទបែបណាទេ ដោយសារការផ្សព្វផ្សាយមិនទាន់បានទូលំទូលាយ និងមានអំណះអំណាងច្បាស់លាស់។
- លោកស្នើសុំឱ្យខាងក្រុមហ៊ុនពេលធ្វើរបាយការណ៍ពេញលេញរួចហើយ ត្រូវធ្វើវេទិការសាធារណៈក្នុងខេត្តព្រះសីហនុនេះតែម្តង ដោយត្រូវមានគ្រប់សមាសភាពអ្នកពាក់ព័ន្ធ និងសហគមន៍ប្រជាពលរដ្ឋ ដើម្បីពិគ្រោះយោបល់ទៅលើរបាយការណ៍នេះថា តើត្រឹមត្រូវអាចទទួលយកបានដែរឬទេ។
- ហើយលោកក៏បានលើកឧទាហរណ៍ទាក់ទងនឹងរោងចក្រធ្យូងថ្មនៅស្ទឹងហាវ មុនដំណើរការមានពាក្យចចាមអាមថា អាចប៉ះពាល់ដល់សុខភាពប្រជាជនក្នុងរយៈចំងាយ១៨គីឡូម៉ែត្រ ដែលធ្វើអោយចំនួនភ្ញៀវទេសចរធ្លាក់ចុះ ដោយមិនហ៊ានមកលេង តែកន្លងផុតប៉ុន្មានខែក្រោយមកដោយសារមិនទាន់មានបញ្ហាដល់ប្រជាជនទើបធ្វើអោយភ្ញៀវទេសចរមកលេងខេត្តព្រះសីហនុវិញ ដល់មកពេលនេះស្រាប់តែមានក្រុមហ៊ុន មកកប់ខ្សែកាប្លិ៍អុបទិចទៀត ដូច្នេះអាចប៉ះពាល់ដល់អារម្មណ៍ភ្ញៀវមកលេង ដែលធ្វើឱ្យប៉ះពាល់ដល់វិស័យទេសចរណ៍ក្នុងខេត្តនេះ តែបើសិក្សាឱ្យបានច្បាស់ទៅផលប៉ះពាល់វាមានតិច ដូចនេះក្រុមហ៊ុនត្រូវធ្វើការផ្សព្វផ្សាយ ពន្យល់ដល់ប្រជាពលរដ្ឋអោយបានច្បាស់ ហើយក្រុមហ៊ុនត្រូវមានរបាយការណ៍សិក្សាវាយតម្លៃផលប៉ះពាល់អោយបានច្បាស់ផងដែរ រួមទាំងប្រភព និងអំណះអំណាង។

Draft

រូបភាព៦.៥៖លោក សុខ សុខុម ក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ



(ប្រភព៖ Creative Green Design Co., Ltd ២០១៥)

Draft

### ៦.២.៨ ការបញ្ចេញមតិយោបល់របស់គណៈកម្មការជាតិសន្តិសុខលំហសមុទ្រ

**លោក ស្វាយ ចន្ធី** អនុប្រធាននាយកដ្ឋាននីតិកម្ម នៃគណៈកម្មការលំហសមុទ្រមានចំណាប់អារម្មណ៍ និងមតិយោបល់ជុំវិញគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍ដូចខាងក្រោម៖

- លោកបានលើកជាសំនួរថា ការបង្កប់ខ្សែកាប្លិ៍អុបទិកនេះ មានប្រទេសណាខ្លះបានប្រើប្រាស់ហើយ? លោកក៏បន្តទៀតថា ប្រព័ន្ធអេឡិចត្រូនិចនេះតែងតែមានផលប៉ះពាល់ដល់បរិស្ថាន គ្រាន់តែវាមានតិច ឬច្រើនតែប៉ុណ្ណោះ ហើយវិធានការទប់ស្កាត់ និងកាត់បន្ថយឱ្យបានល្អយ៉ាងណានោះគឺអាស្រ័យលើក្រុមហ៊ុនដែលជាអ្នកជំនាញ។

- លោកក៏មានប្រសាសន៍ពីបញ្ហាវិទ្យុសកម្មដែរថា វាមាននៅគ្រប់ទីកន្លែង នៅក្បែរយើងគ្រប់គ្នា ហើយយើងមិនអាចជៀសបានទេ ដូចជា អង់តែន រ៉ាដា អ៊ិចរ៉េ ទូរស័ព្ទដែលយើងដាក់ជាប់ខ្លួនរាល់ថ្ងៃសុទ្ធតែមានបញ្ហា តែអ្វីដែលសំខាន់គឺយើងចេះប្រើប្រាស់វាឱ្យមានប្រយោជន៍ដូចម្តេច។
- លោកបានស្នើរសុំឯកសារច្បាប់បន្ថែមទៀត ដើម្បីរាយការណ៍ និងទុកជូនកងទ័ពជើងទឹកមូលដ្ឋានសមុទ្រ និង កងពលតូចលេខ៣១ ដែលការពារគ្រប់កោះទាំងអស់លើដែនសមុទ្រ ដោយសារខ្សែកាប្លិ៍នេះបានរត់កាត់ដែនគ្រប់គ្រងរបស់ពួកគាត់។
- លោកលើកឡើងថា ខ្ញុំក៏មិនដឹងច្បាស់ពីការបែងចែកដែនសមុទ្រខេត្តព្រះសីហនុមានផ្ទៃដីប៉ុន្មានគីឡូម៉ែត្រការ៉េ ខេត្តកំពត និងខេត្តកែបមានប៉ុន្មានទេ ហើយប្រវែងឆ្នេរក៏មិនហ៊ាននិយាយឱ្យប្រាកដប្រជាដែរ តែវាអាចនៅចន្លោះពី៤៥០ ទៅ៥០០គីឡូម៉ែត្រ។
- លោកយល់ឃើញថា ខ្សែកាប្លិ៍អុបទិចដែលមានប្រវែង៤៧០គីឡូម៉ែត រត់ពីសមុទ្រខាងក្រៅ ត្រូវកាត់ឆ្នេរជៀសមិនផុត រួចទើបរត់ឡើងលើគោកទៅស្ថានីយ តែក្រុមហ៊ុនថារត់តាមបណ្តោយឆ្នេរ វានៅដូចមិនសូវច្បាស់ ហើយអ្វីដែលសំខាន់បើរត់កាត់ឆ្នេរ ក្រុមហ៊ុនត្រូវជ្រើសរើសចំណុចណា។
- ក្នុងនាមលោកផ្ទាល់ បានសម្តែងការគាំទ្រលើគម្រោងសាងសង់ខ្សែកាប្លិ៍ ដោយសារប្រទេសដ៏ទៃបានសាងសង់រួចហើយ ឯផលប៉ះពាល់គឺជៀសមិនផុតទេ តែត្រូវមានវិធានការកាត់បន្ថយឱ្យបានល្អ ដើម្បីផលប្រយោជន៍ជាតិ និងប្រជាជន។ ហើយក្រុមហ៊ុនត្រូវពន្យល់ដល់ប្រជាពលរដ្ឋឱ្យបានយល់ច្បាស់ពីគម្រោងខ្សែកាប្លិ៍នេះ ហើយការអភិវឌ្ឍនេះបានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ពួកគាត់ ជៀសវាងការយល់មិនច្បាស់ ឬភ័ន្តច្រឡំ ដែលនាំឱ្យមានបញ្ហាទៅថ្ងៃក្រោយ ដោយលោកបានលើកជាឧទាហរណ៍មួយពាក់ព័ន្ធនឹងការជីកលូរបស់រដ្ឋាករទឹកកាត់មុខផ្ទះរបស់ពួកគាត់ និងមានក្រុមហ៊ុនមួយទៀតទាក់ទងនឹងការបំលែងកាកសំណល់ឱ្យទៅជាទឹកថ្លាបង្ហូរចូលទៅក្នុងសមុទ្រ បានទៅស្នើសុំតប្រព័ន្ធលូនៅមុខផ្ទះរបស់ពួកគាត់ តែគាត់មិនអោយ នេះដោយសារតែការមិនយល់ច្បាស់របស់ពួកគាត់ពីគម្រោង។
- លោកយល់ឃើញថាការកប់ខ្សែកាប្លិ៍អុបទិច នៅជម្រៅ ១,៥ម៉ែត្រ ដូចជានៅរាក់តែបើក្រុមហ៊ុនមានបច្ចេកទេស និងអំណះអំណាងច្បាស់លាស់ហើយក៏មិនជាអ្វីដែរ។
- ជាចុងក្រោយលោក បានស្នើសុំក្រុមហ៊ុនពេលប្រជុំលើកក្រោយអញ្ជើញ ខាងកងទ័ពជើងទឹកមូលដ្ឋានសមុទ្រដែលជាអង្គភាពធំមួយ និងអង្គភាពកងពលតូចលេខ៣១ការពារកោះ និងឆ្នេរ ទទួលបានការអញ្ជើញចូលរួមផង។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

រូបភាព៦.៦៖ លោក ស្វាយ ចន្ធី ក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ



(ប្រភព៖ Creative Green Design Co., Ltd ២០១៥)

Draft

### ៦.២.៦ ការបញ្ចេញមតិយោបល់របស់ខណ្ឌរដ្ឋបាលជលផល

**លោក ឃិន សារ៉ាវុធ** ជាមន្ត្រីខណ្ឌរដ្ឋបាលជលផលមានចំណាប់អារម្មណ៍ និងមតិយោបល់ជុំវិញគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចដូចខាងក្រោម៖

- លោកបានលើកឡើងថា ការបង្កប់ខ្សែកាប្លិ៍ក្រោមបាតសមុទ្រ ខាងជលផលមិនបានស៊ីជម្រៅខាងបច្ចេកទេសទេ តែខាងជលផលបានបែងចែកការនេសាទជាពីរផ្នែកគឺ ទី១ ទាក់ទងនឹងការនេសាទជាលក្ខណៈគ្រួសារ ដែលមានជម្រៅទឹកចាប់ពី០ម៉ែត្រ ដល់២០ម៉ែត្រ ដែលមិនអនុញ្ញាតអោយប្រើឧបករណ៍អួនអូសទេ និងទី២ ទាក់ទងនឹងការនេសាទជាលក្ខណៈសិប្បកម្មដែលមានជម្រៅទឹកចាប់ពី ២០ម៉ែត្រឡើងទៅ ដោយអនុញ្ញាតអោយប្រើឧបករណ៍អួនអូសតែ

មួយមុខគត់ហើយភាគច្រើនការអូសនេះបានត្រឹមតែជម្រៅទឹក៥០ម៉ែត្រដោយសារលទ្ធភាពនៃទូកនេសាទពួកគាត់មានកំរិត។

- ចំណែកការនេសាទរបស់ប្រជាពលរដ្ឋមិនទៀងទាត់ថានៅកន្លែងណាអោយច្បាស់ទេ គឺពួកគាត់នេសាទទៅតាមរដូវកាល តាមចរន្តទឹកជោរ និងនាច ដូច្នេះផលប៉ះពាល់ដល់ការនេសាទប្រាកដជាមាន តែផលប៉ះពាល់តូច ឬធំលោកមិនហ៊ានថាទេ។
- ដោយឡែកការនេសាទតាមតំបន់កោះគឺ គេអនុញ្ញាតអោយនេសាទចាប់ពី ១គីឡូម៉ែត្រចេញពីកោះ ចំណែកក្រុមហ៊ុននឹងបង្កប់ខ្សែកាប្លិ៍នៅចំងាយ ៦០០ ទៅ ៨០០ម៉ែត្រពីកោះ ដូចច្នេះខ្សែកាប្លិ៍កប់ក្នុងបាតសមុទ្រនេះមានចំងាយពីអ្នកនេសាទ ២០០ ទៅ ៤០០ម៉ែត្រ។
- ជើងអួនរបស់ឧបករណ៍នេសាទអាចអូសដល់ភក់ ឬបាតសមុទ្រ ក្នុងជម្រៅ៣តឹកចុះទៅក្នុងដី។
- លោកបានបន្តទៀតថា ចំពោះផ្កាថ្មរស់នៅតែតាមតំបន់កោះ ដែលឃ្លាតឆ្ងាយពីកោះចំងាយ ពី ៥០ ទៅ ១០០ម៉ែត្រ ក្នុងករណីថ្មប្រប្រះទឹក ដោយឡែកចំពោះកោះដែលមានជើងទេចោទមិនសូវមានផ្កាថ្មទេ ព្រោះវាមិនអាចរស់នៅតំបន់ភក់បាន។

រូបភាព៦.៧៖លោក ឃិន សាវ៉ុទក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ



(ប្រភព៖ Creative Green Design Co., Ltd ២០១៥)

### ៦.២.៧ ការបញ្ចេញមតិយោបល់របស់មន្ទីររ៉ែ និងថាមពល

**លោក ម៉ៅ កុលនិរតី** ជាអនុប្រធានរ៉ែ និងថាមពល មានចំណាប់អារម្មណ៍ និងមតិយោបល់ជុំវិញគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចដូចខាងក្រោម៖

- លោកបានលើកឡើងថា ក្រុមហ៊ុនបានមកជួបខាងគាត់ម្តងរួចមកហើយ និងបានសុំយោបល់មួយចំនួនពីលោកផងដែរ ទាក់ទងនឹងរដ្ឋាភិបាលបានដាក់ចេញនូវអាជ្ញាប័នរុករកធនធានរ៉ែដូចជារ៉ែប្រេងកាត និងឧស្ម័ន ហើយលោកក៏បានឱ្យខាងក្រុមហ៊ុនទៅទាក់ទងអគ្គនាយកដ្ឋានប្រេងកាតផងដែរ។

រូបភាព៦.៨៖លោក ម៉ៅ កុលនិរតីក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ



(ប្រភព៖ Creative Green Design Co., Ltd ២០១៥)

Draft

### ៦.២.៨ ការបញ្ចេញមតិយោបល់របស់មន្ទីរធនធានទឹក

**លោក យុត ម៉ន** ជាមន្ត្រីនៃមន្ទីរធនធានទឹក មានចំណាប់អារម្មណ៍ និងមតិយោបល់ជុំវិញគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចដូចខាងក្រោម៖

- លោកបានស្នើឱ្យមានការសិក្សាទៅលើការកប់ខ្សែកាប្លិ៍តាមព្រែកបន្ថែមទៀត បើមានការផ្លាស់ប្តូរពីការកប់តាមឆ្នេរអូរត្រេះ។
- លោកមានការគាំទ្រទៅលើគម្រោងអភិវឌ្ឍន៍ ព្រោះគាត់សង្ឃឹមថា ប្រទេសកម្ពុជានឹងទទួលបានប្រព័ន្ធខ្សែកាប្លិ៍ដើម្បីប្រើប្រាស់ក្នុងប្រទេសឲ្យបានទូលំទូលាយ គ្រប់តំបន់ទាំងអស់ និងមានតំលៃទាប។

រូបភាព៦.៩៖លោក យុត ម៉នក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ



(ប្រភព៖ Creative Green Design Co., Ltd ២០១៥)

### ៦.២.៩ ការបញ្ចេញមតិយោបល់របស់មន្ទីរទេសចរណ៍

**លោក ចាប សុជា** ជាមន្ត្រីនៃមន្ទីរទេសចរណ៍ មានចំណាប់អារម្មណ៍ និងមតិយោបល់ជុំវិញគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចដូចខាងក្រោម៖

- លោកបានអោយជាយោបល់ថា បើក្រុមហ៊ុនចាប់ផ្តើមដំណើរការសាងសង់គួរធ្វើឡើងនៅរដូវមានភ្ញៀវមកលេងតិច ហើយជៀសវាងរដូវមានភ្ញៀវមកលេងច្រើន ចាប់ពីខែ ៦ដល់១២ ដែលអាចប៉ះពាល់ដល់ភ្ញៀវ។ លោកក៏បន្តទៀតថា បើគង់តែតខ្សែកាប្លិ៍នេះ គួតែតទៅតាមព្រៃកវិញ ។
- លោកសូមអោយក្រុមហ៊ុនបង្ហាញផលប៉ះពាល់ឱ្យបានច្បាស់លាស់។

រូបភាព៦.១០៖លោក ចាប សុជា ក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ



(ប្រភព៖ Creative Green Design Co., Ltd ២០១៥)

៦.២.១០ ការបញ្ចេញមតិយោបល់របស់សង្កាត់លេខ៤

**លោក ម៉ែត សារិន**ជាចៅសង្កាត់រងមានចំណាប់អារម្មណ៍ និងមតិយោបល់ជុំវិញ គម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចដូចខាងក្រោម៖

- លោកមានប្រសាសន៍ថា ក្នុងអង្គប្រជុំថ្ងៃនេះគឺពិភាក្សាគ្នាពីផលប៉ះពាល់ តែសព្វថ្ងៃនេះក្រុមហ៊ុនកំពុងអនុវត្តគម្រោងហើយដូចជាទីតាំងស្ថានីយ៍ ដែលស្ថិតក្នុងដីឡូត៍របស់ក្រុមហ៊ុនឡូសាគុនដែលស្ថិតក្នុងរង្វង់៥០ម៉ែត្រនៃដីឆ្នេរសាធារណៈរបស់រដ្ឋ កន្លែងវ៉េហ្គាជាដើមគឺក្រុមហ៊ុនបានដៅគោលដៅរួចរាល់ហើយ ចុះបើការពិភាក្សាក្នុងពេលនេះខុសពីគម្រោងរបស់ក្រុមហ៊ុនថាតើខាងក្រុមហ៊ុននឹងលើកគម្រោងនេះទៅតាមអ្វីដែលអង្គប្រជុំបានលើកឡើងឬយ៉ាងណា? ដោយសារអនុក្រឹត្យថ្មីបានទុកដីចំណីឆ្នេរ៥០ម៉ែត្រជាដីសាធារណៈរបស់រដ្ឋ ហើយក្នុងគម្រោងអភិវឌ្ឍន៍របស់ក្រសួងទេសចរណ៍នឹងទុកតំបន់ឆ្នេរអូរត្រេះទៅជាឆ្នេរគំរូ ហើយរាជរដ្ឋាភិបាលនឹងបង្កើតផ្លូវរបៀងមាត់សមុទ្រ ចាប់ពីខេត្តកំពតរហូតដល់ខេត្តកោះកុង ដូច្នេះគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចនេះនឹងមានផលប៉ះពាល់អ្វីខ្លះ?
- លោកបានបន្តទៀតថា ការបង្កប់ខ្សែកាប្លិ៍បានកាត់តាមបណ្តោយផ្លូវពីរ គឺផ្លូវគ្រួសក្រហម និងផ្លូវកៅស៊ូ ហើយផ្លូវរបៀងមាត់សមុទ្រនឹងកាត់តាមផ្លូវទាំងពីរ ម្យ៉ាងជម្រៅដែលក្រុមហ៊ុននឹងបង្កប់ខ្សែកាប្លិ៍គឺ ១.២ម៉ែត្រ តើក្រុមហ៊ុនត្រូវដោះស្រាយយ៉ាងណា?
- ជាចុងក្រោយលោក ធ្វើការគាំទ្រខាងមន្ទីរបរិស្ថាន ដែលស្នើអោយខាងភាគីក្រុមហ៊ុនលើកទីតាំងបង្កប់ខ្សែកាប្លិ៍ទៅតាមបណ្តោយព្រែកវិញ ដោយសារទីតាំងស្ថានីយ៍នៅក្បែរព្រែក ម្យ៉ាងវិញទៀត ប្លង់គម្រោងសួនឆ្នេរគំរូអូរត្រេះ និងផ្លូវរបៀងមាត់សមុទ្រនៅមិនទាន់ដឹងច្បាស់ថារៀបចំបែបណា។ ហើយបើល្អ ក្រុមហ៊ុនគួរសិក្សាការកប់ខ្សែទៅតាមតំបន់ស្ទឹងហាវក៏បាន។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

រូបភាព៦.១១៖ លោក ប៉ែត សារិនក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ



(ប្រភព៖ Creative Green Design Co., Ltd ២០១៥)

### ៦.២.១១ ការបញ្ចេញមតិយោបល់របស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសូរិយោដី ខេត្តព្រះសីហនុ

**លោក ឌិម សេខ** ជាអនុប្រធានមន្ទីរមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសូរិយោដី ខេត្តព្រះសីហនុមានចំណាប់អារម្មណ៍ និងមតិយោបល់ជុំវិញគម្រោងអភិវឌ្ឍន៍ ខ្សែកាប្លិ៍អុបទិចដូចខាងក្រោម៖

- លោកមានប្រសាសន៍ថា ផលប៉ះពាល់តែងតែមាន ម៉្យាងខាងក្រុមហ៊ុនបានរៀបចំប្លង់ស្ថាបត្យកម្មរួចរាល់ហើយ ដូច្នេះការដែលស្នើឱ្យក្រុមហ៊ុនដូរទៅតំបន់ស្ទឹងហាវវិញគឺមានការលំបាកបន្ថែមពីនេះខាងក្រុមហ៊ុនបានពន្យល់ប្រាប់លោកពីបច្ចេកទេសក្នុងការកប់ថា បើប្តូរទៅកប់តាមបណ្តោយព្រែកគឺខ្សែកាប្លិ៍ត្រូវបត់ មុំ៦០ដឺក្រេ អាចធ្វើឱ្យប្រព័ន្ធខ្សែកាប្លិ៍ដំណើរការមិនល្អ។
- ចំណែកផលចំណេញពីការកប់ខ្សែកាប្លិ៍ គឺតម្លៃប្រើប្រាស់អ៊ីនធឺណែតទាបជាមុន។

រូបភាព៦.១២៖ លោក ជិបសេង ក្នុងកិច្ចប្រជុំពិគ្រោះយោបល់នៅសាលាខេត្តព្រះសីហនុ



(ប្រភព៖ Creative Green Design Co., Ltd ឆ្នាំ២០១៥)

Draft

### ៦.២.១២ ការបញ្ចេញមតិយោបល់របស់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ

**លោក ឆេន ហ៊ាន** ជាអនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈមានចំណាប់អារម្មណ៍ និងមតិយោបល់ជុំវិញគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចដូចខាងក្រោម៖

- ប្រទេសកម្ពុជាមានប្រវត្តិសាស្ត្រខាងបណ្តាញផ្លូវទឹក ដ៏សំខាន់តាំងពីយូរលង់មកហើយ ហើយបណ្តាញផ្លូវទឹកនេះគឺជាផ្នែកមួយដ៏សំខាន់នៃបេតិកភណ្ឌវប្បធម៌កម្ពុជា។ នៅឆ្នាំ២០០៧ ដោយសារកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាយូណេស្កូឆ្នាំ២០០១ ស្តីពីការការពារបេតិកភណ្ឌក្រោមទឹក។ ដូចនេះរាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវសុឆន្ទៈដើម្បីកំណត់បេតិកភណ្ឌវប្បធម៌ក្រោមទឹក និងការពារសម្រាប់មនុស្សជំនាន់ក្រោយ។

- កន្លងមកនៅដែនសមុទ្រកម្ពុបានជាធ្លាប់មានសំពៅ ទូក និងនាវាបានលិចនៅក្នុងបាតសមុទ្រនៃប្រទេសកម្ពុជានេះ។ ជាក់ស្តែនៅក្បែរកោះឬស្សីធ្លាប់មានសំពៅលិច ធ្លាប់មានយន្តហោះធ្លាក់នៅ៥គីឡូម៉ែត្រពីព្រែកត្រែង (ព្រែកត្រែងមានចំងាយ៩គ.មពីក្រុងព្រះសីហានុ) ធ្លាប់មានសំពៅលិច ២០គីឡូម៉ែត្រពីកោះស្តេច និងមានការលិចនៅតំបន់ផ្សេងៗទៀតជាច្រើន។
- ម្យ៉ាងទៀតប្រជានេសាទក៏ធ្លាប់ប្រទះឃើញ ចំណែកកប៉ាល់ ទូក និងសំពៅដែលធ្លាប់លិចផងដែរ។
- ជាចុងក្រោយសំណូមពរដល់ក្រុមហ៊ុនវិនិយោគ ប្រសិនបើនៅពេលជីកបង្កប់ខ្សែកាប្លិ៍ ជួបប្រទះនូវសម្បត្តិវប្បធម៌ក្រោមទឹក ធ្វើការផ្តល់ដំណឹងដល់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈផង។
- សូមធ្វើការគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍ និងសូមឲ្យការអភិវឌ្ឍន៍នេះនឹងមានដំណើរការបានឆាប់រហ័ស។

រូបភាព៦.១៣៖ លោក ឆេង ហ៊ាន ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ



(ប្រភព៖ Creative Green Design Co., Ltd ឆ្នាំ២០១៦)

៦.២.១៣ ការបញ្ចេញមតិយោបល់របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

**លោក ចូវ ខេមរា** ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុមាន មតិយោបល់ជុំវិញគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចក្រោមបាតសមុទ្រកម្ពុជាដូចខាងក្រោម៖

- លោកមានការពេញចិត្ត និងសប្បាយរីករាយ ដែលក្រុមហ៊ុនបានធ្វើការវិនិយោគ លើគម្រោងបង្កប់ខ្សែកាប្លិ៍អុបទិចក្រោមបាតសមុទ្រនេះ ព្រោះគម្រោងនេះលោកសង្ឃឹមថា នឹងផ្តល់ការងារមួយចំនួនដល់ប្រជាពលរដ្ឋ និងទទួលបាននូវបច្ចេកវិទ្យានិងលឿនរហ័សទាន់ចិត្តសម្រាប់ប្រើប្រាស់ក្នុងប្រទេសកម្ពុជាយើងនេះ។
- ក្រុមហ៊ុនក៏ត្រូវធ្វើការចុះបញ្ជីការ ធ្វើបញ្ជីរធានារ៉ាប់រងលើគ្រោះថ្នាក់ការងារ ធ្វើបញ្ជីរធានារ៉ាប់រងលើសុខភាពបុគ្គលិក និងកម្មករផងដែរ។ ម្យ៉ាងទៀត ក្រុមហ៊ុនត្រូវកំណត់អាយុធ្វើការងាររបស់បុគ្គលិក និងកម្មករមិនឲ្យក្រោមអាយុ ១៨ឆ្នាំ។
- ក្រុមហ៊ុនក៏ត្រូវផ្តល់ឈ្មោះក្រុមហ៊ុន Sub-Contractor សម្រាប់ជាពត៌មានដល់មន្ទីរផងដែរ។
- ក្រុមហ៊ុនត្រូវធ្វើសៀវភៅការងារ ទាំងបរទេស និងក្នុងប្រទេស។
- ជាចុងក្រោយ លោកសូមធ្វើការគាំទ្រទៅលើគម្រោងអភិវឌ្ឍន៍នេះ។

រូបភាព៦.១៥៖ លោក **ចូវ ខេមរា** ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ



(ប្រភព៖ Creative Green Design Co., Ltd ឆ្នាំ២០១៦)

៦.២.១៤ ការបញ្ចេញមតិយោបល់របស់មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះសីហនុ

**លោក ជ្រា ថារ៉ាវុធ** អនុប្រធានមន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្តព្រះសីហនុ មានមតិយោបល់ជុំវិញគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចក្រោមបាតសមុទ្រកម្ពុជាដូចខាងក្រោម៖

- ការបង្កប់ខ្សែកាប្លិ៍អុបទិចនៅលើគោក គឺក្រុមហ៊ុនបានធ្វើការសហការជាមួយ ខាងមន្ទីរសាធារណៈការខ្ញុំដើម្បីសាងសង់រ៉េហ្គា នៅតំបន់ឆ្នេរអូរត្រេះចំនួន៩ទីតាំង។ ការសាងសង់នេះ ក្រុមហ៊ុនក៏មានការសុំច្បាប់ត្រឹមត្រូវផងដែរ។
- សម្រាប់ការសាងសង់រ៉េហ្គា មិនធ្វើឲ្យមានការប៉ះពាល់ដល់ផ្លូវដែលមានស្រាប់ទេ ព្រោះការកប់នេះ គឺមានចំងាយ១០ម៉ែត្រពីអ័ក្សផ្លូវ។
- ក្រោយពីការជីកកប់ខ្សែកាប្លិ៍ រួចក្រុមហ៊ុនបានធ្វើការលប់ ដី ឲ្យរាបស្មើវិញ ដែលមិនធ្វើឲ្យមានការប៉ះពាល់ដល់ប្រព័ន្ធផ្លូវដែលមានស្រាប់នោះទេ។
- ក្រុមហ៊ុនបានធ្វើផ្លូវ ១ខ្សែដើម្បីធ្វើដំណើរចូលក្នុងស្ថានីយ៍ខ្សែកាប្លិ៍ ដែលសាធារណៈជនក៏អាចប្រើប្រាស់ផ្លូវនេះ បានដែរ។
- ទាក់ទងនឹង ប្រព័ន្ធផ្លូវទឹក គឺមិនសូវមានសកម្មភាពមម៉ាញឹកនោះទេ ដែលមិនធ្វើឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរនៅពេលជីកបង្កប់ខ្សែកាប្លិ៍ក្រោមបាតសមុទ្រ។

រូបភាព៦.១៥៖ លោក **ជ្រា ថារ៉ាវុធ** ក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈ



(ប្រភព៖ Creative Green Design Co., Ltd ឆ្នាំ២០១៦)

Draft

### ៦.២.១៨ ការបញ្ចេញមតិយោបល់របស់មន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រះសីហនុ

**លោក ជួស សុធា** ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រះសីហនុ មានមតិយោបល់ជុំវិញគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចក្រោមបាតសមុទ្រកម្ពុជាដូចខាងក្រោម៖

- កន្លងមកក្រុមហ៊ុន Telcotech Ltd បានធ្វើការទំនាក់ទំនង ស្នើរសុំ និងសហការល្អជាមួយមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្តព្រះសីហនុខ្ញុំ។
- គម្រោងនេះនឹងផ្តល់នូវព័ន្ធទំនាក់ទំនងដែលមានតំលៃសមរម្យ និងជួយជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចផងដែរ។
- គម្រោងនេះអាចនឹងមានការប៉ះពាល់ទៅលើបរិស្ថានមួយចំនួន ជាពិសេសជីវៈចំរុះនៅក្នុងទឹក ដូចក្រុមហ៊ុនត្រូវសហការជាមួយអ្នកជំនាញលើធនធានសមុទ្រដើម្បីសិក្សាឲ្យបានច្បាស់លាស់។
- គាត់មានការគាំទ្រទៅលើគម្រោងអភិវឌ្ឍន៍នេះ ព្រោះគម្រោងនេះពិតមានផលប្រយោជន៍ច្រើនសម្រាប់ប្រទេសកម្ពុជាយើង ព្រោះជាគម្រោងទី១ ដែលប្រទេសកម្ពុជាបានតភ្ជាប់បណ្តាញខ្សែកាប្លិ៍ក្រោមបាតសមុទ្រ។

រូបភាព៦.១៦៖ លោក ជួស សុធា ប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍



(ប្រភព៖ Creative Green Design Co., Ltd ឆ្នាំ២០១៦)

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

## តារាង ៦.១ សេចក្តីសង្ខេបយោបល់ និងសំណូមពរ

| ល.រ | នាម+គោត្តនាម | តួនាទី | រូបភាព | មតិយោបល់ |
|---|---|---|---|---|
| ១ | ឯកឧត្តម<br>ឈិន សេងងួន | អភិបាលរងខេត្ត<br>ព្រះសីហនុ |  | • ឯកឧត្តម បានលើកជាសំនួរថា តើខ្សែកាប្លិ៍ដែលរត់កាត់ដែនទឹកសមុទ្រខេត្តព្រះសីហនុមានប៉ុន្មានគីឡូម៉ែត្រ? ហើយត្រូវមានផែនទីសម្រាប់បង្ហាញផង ដោយមានភ្ជាប់និយាមការ អោយបានច្បាស់ និងត្រូវមានអ្វីជាសម្គាល់បញ្ជាក់។<br>• ពេលផែនទីបានធ្វើរួចហើយត្រូវ ឆ្លងកាត់ការពិនិត្យពីគ្រប់ស្ថាប័នពាក់ព័ន្ធ។<br>• បារម្ភពីការត្រួតស៊ីគ្នារវាង ខ្សែកាប្លិ៍ និងការធ្វើសូនគំរូអូរគ្រេះ ទាក់ទងនឹងជម្រៅកប់ខ្សែកាប្លិ៍។<br>• ត្រូវមានប្លង់ខ្សែកាប្លិ៍រត់ពីណាទៅណាកប់ក្នុងជម្រៅប៉ុន្មាន អោយបានច្បាស់សម្រាប់គំកល់នៅខេត្ត។<br>• ឯកឧត្តម បារម្ភពីរបាយការណ៍ និងឯកសារផ្សេងៗនៅមិនទាន់មាន ប្រភពច្បាស់លាស់។<br>• តើកាបង្កប់ខ្សែកាប្លិ៍មានផលប៉ះពាល់អ្វីខ្លះដល់ពូជត្រី<br>• តើគម្រោងនេះបានផ្តល់ផលប្រយោជន៍អ្វីខ្លះដល់ប្រទេសជាតិ ក៏ដូចជាប្រជាពលរដ្ឋ។ |

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ល.រ | នាម+គោត្តនាម | តួនាទី | រូបភាព | មតិយោបល់ |
|---|---|---|---|---|
| ២ | លោក ឡេ ហុកលាន | បុគ្គលិកក្រុមហ៊ុនតែលកូថេក |  | • ឆ្លើយតបទៅនឹងសំនួរទីតាំងសាងសង់ ខាងក្រុមហ៊ុនបានទាក់ទងទៅខាងមន្ទីរដែនដីរួចហើយ។<br>• ចំពោះប្លង់អូរជីកចេញពីស្ថានីយទៅមាត់សមុទ្របានការអនុញ្ញាតពីខេត្ត និងក្រសួងសាធារណៈការដឹងឮ។<br>• ខាងក្រុមហ៊ុនមានជាគម្រោងបឋមសម្រាប់ធ្វើការសិក្សាផ្ទាល់លើសមុទ្រ បន្ទាប់ពីសិក្សាចប់ទើបក្រុមហ៊ុនចេញជាលទ្ធផល និយាមការ ពិតប្រាកដមួយ សម្រាប់ប្រគល់ទៅក្រសួងពាក់ព័ន្ធ។<br>• ចំពោះបញ្ហាសាងសង់សូនគំរូ ក្រុមហ៊ុនបានស្នើសុំប្លង់គំរូសាងសង់សូនសម្រាប់យកទៅសិក្សាបន្ថែមទៀត ដើម្បីប្រៀបធៀប និងកែសម្រួល។ |
| ៣ | លោក សាមុត សុធារិទ្ធ | ប្រធានមន្ទីរបរិស្ថានខេត្ត |  | • ការតបណ្តាញខ្សែកាប្លិ៍ ពេលចាប់ផ្តើមដំណើរការ រៀបចំនិងតបណ្តាញ ក្រុមហ៊ុនគួរមានលេខ GPS សិក្សាពីផលប៉ះពាល់ គួរមានរូបភាព វីដេអូពីសកម្មភាព និងប្រភពឯកសារ និងការទទួលស្គាល់ដោយស្ថាប័នណាខ្លះ។<br>• ការរត់ខ្សែបណ្តាញពីឆ្នេរមកស្ថានីយ គួតែបញ្ចៀសពីឆ្នេរ ដោយតទៅតាមអូរ រួចចូលទៅស្ថានីយវិញ ដោយលោកបារម្ភពីការជីកកកាយខ្សែកាប្លិ៍ពេលមានការអភិវឌ្ឍតំបន់ឆ្នេរអូរគ្រោះកាន់តែខ្លាំង។ |

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ល.រ | នាម+គោត្តនាម | តួនាទី | រូបភាព | មតិយោបល់ |
|---|---|---|---|---|
| ៤ | លោក សុខ សុខុម | ប្រធានអង្គការ CNRO |  | • ឆ្នេរអូរគ្រែះបានចាត់ទុកជាឆ្នេរស្អាតបំផុតដូចច្នេះខ្សែកាប្លិ៍គួរត់ទៅកន្លែងផ្សេង។<br>• ការសិក្សាគួតែធ្វើឡើងអោយបានស៊ីជម្រៅ (ឧទាហរណ៍ ផលប៉ះពាល់ វិទ្យុសកម្ម មេកានិកក្នុងតំបន់ ឬប៉ះពាល់ដល់អ្នកនេសាទ) បើមិនដូចច្នេះ អ្នកណាទទួលខុសត្រូវលើផលប៉ះពាល់ទាំងអស់នេះ។<br>• ក្រុមហ៊ុនគួធ្វើការផ្សព្វផ្សាយ ពន្យល់ដល់ភ្ញៀវទេសចរឱ្យបានដឹងច្បាស់ពីគម្រោង និងផលប៉ះពាល់មានក្នុងកំរិតណា ជៀសវាងការយល់ខុសធ្វើឱ្យភ្ញៀវមិនហ៊ានមកលេងតំបន់ឆ្នេរដូចកាលទើបសាងសង់រោងចក្រធ្យូងថ្មជាដើម។ |
| ៥. | លោកស្វាយ ចន្ទី | អនុនាយកដ្ឋាននីតិកម្ម គណកម្មការជាតិសន្តិសុខលំហសមុទ្រ (NCMS) |  | • ការបង្កប់ខ្សែកាប្លិ៍អុបទិកនេះ មានប្រទេសណាខ្លះបានប្រើប្រាស់ហើយ? ហើយក្រុមហ៊ុនមានវិធានការដោះស្រាយបែបណា?<br>• លោកបានស្នើសុំឯកសារច្បាប់បន្ថែមទៀត និងក្នុងកិច្ចប្រជុំលើកក្រោយ ត្រូវអញ្ជើញកងទ័ពជើងទឹកមូលដ្ឋានសមុទ្រ និង កងពលតូចលេខ៣១ ការពារកោះឆ្នេរចូលរួមផង។<br>• ខ្សែកាប្លិ៍អុបទិច ត្រូវវត់កាត់ឆ្នេរជៀសមិនផុត រួចទើបរត់ |

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ល.រ | នាម+គោត្តនាម | តួនាទី | រូបភាព | មតិយោបល់ |
|---|---|---|---|---|
| | | | | ឡើងលើគោក ទៅស្ថានីយ៍ តែក្រុមហ៊ុនថារត់តាមបណ្តោយឆ្នេរ វានៅដូចមិនសូវច្បាស់។<br>• លោកបានគាំទ្រដល់ការសាងសង់ ដើម្បីការអភិវឌ្ឍប្រទេស តែក្រុមហ៊ុនត្រូវសិក្សាពីផលប៉ះពាល់ និងដំណោះស្រាយ ដោយពន្យល់ដល់ប្រជាពលរដ្ឋឱ្យបានច្បាស់ ជៀសវាងការយល់ខុស។ |
| ៦. | លោកឃិន សារ៉ាវុធ | មន្ត្រីខណ្ឌរដ្ឋបាលជលផល |  | • ខាងជលផលបានបែងចែកការនេសាទជាពីរផ្នែក គឺការនេសាទជាលក្ខណៈគ្រួសារ (០ម៉ែត្រដល់២០ម៉ែត្រ) និងការនេសាទជាលក្ខណៈសិប្បកម្ម ប្រើឧបករណ៍អូនអូសតែមួយមុខគត់(២០ម៉ែត្រឡើងទៅ) ហើយពេលអូសជើងអូនអាចកប់ចូលភក់ឬបាតសមុទ្រប្រហែល៣តឹក។ នៅតាមកោះអនុញ្ញាតអោយនេសាទចំងាយ ចាប់ពី១គីឡូម៉ែត្រពីកោះ ហើយផ្កាថ្មរស់នៅតាមកោះដែលមានចំងាយពី ៥០-១០០ម៉ែត្រ។<br>• ឯក្រុមហ៊ុននឹងបង្កប់ខ្សែកាប្លិ៍នៅចំងាយ ៦០០ ទៅ ៨០០ ម៉ែត្រពីកោះ ដូចច្នេះខ្សែកាប្លិ៍កប់ក្នុងបាតសមុទ្រនេះមានចំងាយពីអ្នកនេសាទ ២០០ ទៅ ៤០០ម៉ែត្រ។<br>• ប្រជាជននេសាទទៅតាមរដូវកាល តាមចរន្តទឹកជោរ និងនាច ដូច្នេះផលប៉ះពាល់ដល់ការនេសាទប្រាកដជាមាន |

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ល.រ | នាម+គោត្តនាម | តួនាទី | រូបភាព | មតិយោបល់ |
|---|---|---|---|---|
| | | | | តែផលប៉ះពាល់តូច ឬធំលោកមិនហ៊ានថាទេ។ |
| ៧. | លោក ម៉ៅ កុលនិរតី | អនុប្រធានមន្ទីររ៉ែ និងថាមពល |  | • លោកបានលើកឡើងថា ក្រុមហ៊ុនបានមកជួបខាងគាត់ម្តងរួចមកហើយ និងបានសុំយោបល់មួយចំនួនពីលោកផងដែរ ទាក់ទងនឹងរដ្ឋាភិបាលបានដាក់ចេញនូវអាជ្ញាប័នរុករកធនធានរ៉ែ ដូចជាប្រេងកាត ឬឧស្ម័ន ហើយលោកក៏បានឱ្យខាងក្រុមហ៊ុនទៅទាក់ទងអគ្គនាយកដ្ឋានប្រេងកាត។ |
| ៨. | លោកឃុត ម៉ន | មន្ទីរធនធានទឹក |  | • លោកស្នើឱ្យមានការសិក្សាទៅលើការកប់ខ្សែកាប្លិ៍ តាមព្រែកបន្ថែមទៀត បើមានការផ្លាស់ប្តូរពីការកប់តាមឆ្នេរអូរគ្រែះ។ |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ល.រ | នាម+គោត្តនាម | តួនាទី | រូបភាព | មតិយោបល់ |
|---|---|---|---|---|
| ៩. | លោក ចាប សុជា | មន្ទីរទេសចរណ៍ខេត្ត |  | • លោកបានអោយជាយោបល់ថា បើក្រុមហ៊ុនចាប់ផ្តើមដំណើរការសាងសង់គួរធ្វើឡើងនៅរដូវមានភ្ញៀវមកលេងតិច ហើយជៀសវាងរដូវមានភ្ញៀវមកលេងច្រើន ចាប់ពីខែ ៦ដល់១២ ដែលអាចប៉ះពាល់ដល់ភ្ញៀវ។ លោកក៏បន្តទៀតថា បើគង់តែតខ្សែកាប្លិ៍នេះ គួតែតទៅតាមព្រែកវិញ។<br>• លោកសូមអោយក្រុមហ៊ុនបង្ហាញផលប៉ះពាល់ឱ្យបានច្បាស់លាស់។ |
| ១០ | លោក ប៉ែត សារិន | ចៅសង្កាត់រងលេខ ៤ |  | • លោកមានប្រសាសន៍ថា សព្វថ្ងៃនេះក្រុមហ៊ុនកំពុងអនុវត្តគម្រោងហើយ ចុះបើបានការផ្លាស់ប្តូរខុសពីគម្រោងដើម តើក្រុមហ៊ុននឹងលើកគម្រោងនេះទៅតាមមតិដែលបានលើកឡើងក្នុងកិច្ចប្រជុំឬយ៉ាងណា?<br>• ការបង្កប់ខ្សែកាប្លិ៍មានជម្រៅ១.២ម៉ែត្របានកាត់តាមបណ្តោយផ្លូវពីរ គឺផ្លូវគ្រួសក្រហម និងផ្លូវកៅស៊ូ និងទៅថ្ងៃអនាគតរដ្ឋនឹងសាងសង់ផ្លូវបៀងមាត់សមុទ្រដែលនឹងកាត់តាមផ្លូវទាំង២ ដូច្នេះគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចនេះនឹងមានផលប៉ះពាល់អ្វីខ្លះ?<br>• លោក ស្នើអោយខាងភាគីក្រុមហ៊ុនលើកទីតាំងបង្កប់ខ្សែកាប្លិ៍ទៅតាមបណ្តោយព្រែកវិញ។ |

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ល.រ | នាម+គោត្តនាម | តួនាទី | រូបភាព | មតិយោបល់ |
|---|---|---|---|---|
| ១១ | លោក ជិប សេង | អនុប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី |  | • លោកបានមានប្រសាសន៍ថា ផលប៉ះពាល់តែងតែមានម៉្យាងខាងក្រុមហ៊ុនបានរៀបចំប្លង់ស្លាបត្យកម្មរួចរាល់ហើយ ដូច្នេះការដែលស្នើឱ្យក្រុមហ៊ុនដូរទៅតំបន់ស្ទឹងហាវវិញគឺមានការលំបាក បន្ថែមពីនេះខាងក្រុមហ៊ុនបានពន្យល់ប្រាប់លោកពីបច្ចេកទេសក្នុងការកប់ថា បើប្តូរទៅកប់តាមបណ្តោយព្រែកគឺខ្សែកាប្លិ៍ត្រូវបត់ មុំ៦០ដឺក្រេ អាចធ្វើឱ្យប្រព័ន្ធខ្សែកាប្លិ៍ដំណើរការមិនល្អ។<br>• ចំណែកផលចំណេញពីការកប់ខ្សែកាប្លិ៍ គឺតម្លៃប្រើប្រាស់អ៊ីនធឺណែតទាបជាមុន។ |
| ១២ | លោក ឆេន ហ៊ាន | អនុប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈ |  | • នៅឆ្នាំ២០០៧ ដោយសារកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាយូណេស្កូឆ្នាំ២០០១ ស្តីពីការការពារបេតិកភណ្ឌក្រោមទឹក។ ដូចនេះរាជរដ្ឋាភិបាលកម្ពុជាបានបង្ហាញនូវសុឆន្ទៈដើម្បីកំណត់បេតិកភណ្ឌវប្បធម៌ក្រោមទឹក និងការពារសម្រាប់មនុស្សជំនាន់ក្រោយ។<br>• ដែនសមុទ្រកម្ពុជា ធ្លាប់មានសំពៅ ទូក និងនាវាលិចដែលនៅក្បែរកោះឬស្សីធ្លាប់មានសំពៅលិច ធ្លាប់មានយន្តហោះធ្លាក់ (៥គ.មពីព្រែកគ្រែង) ធ្លាប់មានសំពៅលិច (២០គ.មពីកោះស្តេច) និងមានការលិចនៅតំបន់ផ្សេងៗទៀតជាច្រើន។ |

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ល.រ | នាម+គោត្តនាម | តួនាទី | រូបភាព | មតិយោបល់ |
|---|---|---|---|---|
| | | | | • ប្រជានេសាទធ្លាប់ប្រទះឃើញ ចំណែកកប៉ាល់ ទូក និងសំពៅដែលធ្លាប់លិច។ <br> • សំណូមពរដល់ក្រុមហ៊ុនវិនិយោគ ប្រសិនបើនៅពេលជីកបង្កប់ខ្សែកាប្លិ៍ ជួបប្រទះនូវសម្បត្តិវប្បធម៌ក្រោមទឹក ធ្វើការផ្តល់ដំណឹងដល់មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈផង។ <br> • សូមធ្វើការគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍ និងសូមឲ្យការអភិវឌ្ឍន៍នេះនឹងមានដំណើរការបានឆាប់រហ័ស។ |
| ១៣ | លោក ចូវ ខេមរា | ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |  | • លោកមានការពេញចិត្ត ព្រោះគម្រោងនេះលោកសង្ឃឹមថា នឹងផ្តល់ការងារមួយចំនួនដល់ប្រជាពលរដ្ឋ និងទទួលបាននូវបច្ចេកវិទ្យានិងល្បឿនរហ័សទាន់ចិត្ត។ <br> • ក្រុមហ៊ុនក៏ត្រូវធ្វើការចុះបញ្ជីរការ ធ្វើបញ្ជីរធានារ៉ាប់រងលើគ្រោះថ្នាក់ការងារ ធ្វើបញ្ជីរធានារ៉ាប់រងលើសុខភាពបុគ្គលិក និងកម្មករ និងកំណត់អាយុធ្វើការងាររបស់បុគ្គលិក-កម្មករមិនឲ្យក្រោមអាយុ ១៨ឆ្នាំ។ <br> • ក្រុមហ៊ុនក៏ត្រូវផ្តល់ឈ្មោះក្រុមហ៊ុន Sub-Contractor សម្រាប់ជាពត៌មានដល់មន្ទីរផងដែរ។ <br> • ជាចុងក្រោយ លោកសូមធ្វើការគាំទ្រទៅលើគម្រោងអភិវឌ្ឍន៍នេះ។ |

Draft

Creative Green Design Co., Ltd
Social-Environmental Researchs
Quality Researchers

#322P, St.271Z, Sk.Tek Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

| ល.រ | នាម+គោត្តនាម | តួនាទី | រូបភាព | មតិយោបល់ |
|---|---|---|---|---|
| ១៤ | លោក ជ្រា ថារ៉ាវុធ | អនុប្រធានមន្ទីរសាធារណៈការ និង ដឹកជញ្ជូន |  | • ការបង្កប់ខ្សែកាប្លិ៍អុបទិចនៅលើគោក គឺក្រុមហ៊ុនបាន សុំច្បាប់ត្រឹមត្រូវ និងសហការជាមួយ ខាងមន្ទីរសាធារណៈ ដើម្បីសាងសង់។<br>• សម្រាប់ការសាងសង់រ៉េហ្គា មិនធ្វើឲ្យមានការប៉ះពាល់ដល់ផ្លូវដែលមានស្រាប់ទេ ព្រោះការកប់នេះ គឺមានចំងាយ១០ម៉ែត្រពីអ័ក្សផ្លូវ។<br>• ក្រោយពីការជីកកប់ខ្សែកាប្លិ៍ រួចក្រុមហ៊ុនបានធ្វើការលប់ដី ឲ្យរាបស្មើរវិញ។<br>• ក្រុមហ៊ុនបានធ្វើផ្លូវ ១ខ្សែដើម្បីធ្វើដំណើរចូលក្នុងស្ថានីយ៍ខ្សែកាប្លិ៍ ដែលសាធារណៈជនក៏អាចប្រើប្រាស់ផ្លូវនេះបានដែរ។<br>• ទាក់ទងនឹង ប្រព័ន្ធផ្លូវទឹក គឺមិនសូវមានសកម្មភាពមម៉ាញឹកនោះទេ ដែលមិនធ្វើឲ្យមានការប៉ះពាល់ធ្ងន់ធ្ងរនៅពេលជីកបង្កប់ខ្សែកាប្លិ៍ក្រោមបាតសមុទ្រ។ |
| ១៥ | លោក ជួស សុធា | ប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ |  | • កន្លងមកក្រុមហ៊ុន Telcotech Ltd បានធ្វើការទំនាក់ទំនងស្នើរសុំ និងសហការល្អ។<br>• គម្រោងនេះនឹងផ្តល់នូវព័ន្ធទំនាក់ទំនងដែលមានតំលៃសមរម្យ និងជួយជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចផងដែរ។<br>• ត្រូវសហការជាមួយអ្នកជំនាញលើធនធានសមុទ្រ<br>• គាត់មានការគាំទ្រទៅលើគម្រោងអភិវឌ្ឍន៍នេះ។ |

Draft

## ៦.៣ ការជួបសម្ភាសន៍ និងពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន

នៅថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០១៥ វេលាម៉ោង ៨:៣០នាទីព្រឹក ក្រុមការងារ **គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ** បានជួបសម្ភាសន៍ផ្ទាល់ជាមួយអាជ្ញាធរមូលដ្ឋានក្នុងភូមិអូរគ្រេះ។ ការសម្ភាសន៍ធ្វើឡើងនៅផ្ទះលោក មេភូមិទី៦ (ភូមិអូរគ្រេះ) ព្រោះភូមិនេះទើបបង្កើតថ្មី និងមិនទាន់មានទីស្នាក់ភូមិនៅឡើយ។ ការជួបសម្ភាសន៍ផ្ទាល់នេះមានគោលបំណងផ្សព្វផ្សាយ ពិគ្រោះយោបល់ និងការលើកជាសំណើរផ្សេងៗដែលពាក់ព័ន្ធនឹង គម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចក្រោមបាតសមុទ្រ របស់ក្រុមហ៊ុន TELCOTECH, Ltd ដែលមានស្ថានីយ៍ស្ថិតក្នុងភូមិអូរគ្រេះ។ ការពិគ្រោះយោបល់នេះមានសំណួរ និងមតិយោបល់ដែលពាក់ព័ន្ធជាមួយគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិច មួយចំនួនដូចខាងក្រោមៈ

**មតិយោបល់របស់មេភូមិអូរគ្រេះ**

លោក **ជា ទឹុខ** ភេទប្រុស មានអាយុ ៥០ឆ្នាំ មានតួនាទីជាប្រធានភូមិអូរគ្រេះ បានផ្តល់បទសម្ភាសន៍ និងមតិយោបល់ទាក់ទងនឹងគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចកប់ក្រោមបាតសមុទ្រដូចខាងក្រោមៈ

- លោកបានគាំទ្រគម្រោងអភិវឌ្ឍន៍ខ្សែកាប្លិ៍អុបទិចនេះ ព្រោះការអភិវឌ្ឍតែងនាំមកនូវភាពរីកចម្រើនដល់ប្រជាជន និងប្រទេសជាតិ ហើយអ្វីដែលសំខាន់នោះ គម្រោងនេះនឹងអាចជួយឱ្យការប្រើប្រាស់ប្រព័ន្ធអ៊ីនធឺណែតកាន់តែមានភាពងាយស្រួល លឿន និងមានតម្លៃថោកជាងមុនស្របពេលតម្រូវការប្រើប្រាស់បណ្តាញអ៊ីនធឺណែតកាន់តែច្រើនឡើងជារៀងរាល់ថ្ងៃ។
- លោកបានលើកឡើងពីបញ្ហាជីកកកាយផ្លូវសម្រាប់កប់ខ្សែកាប្លិ៍ គឺសូមឱ្យក្រុមហ៊ុនធ្វើការបង្កប់ និងអ៊ុតផ្លូវឱ្យបានស្អាតវិញ ជៀសវាងមានធូលីហុយនាំឱ្យមានភាពលំបាកក្នុងការធ្វើដំណើរ និងប៉ះពាល់ដល់សុខភាពអ្នកធ្វើដំណើរ និងអ្នកលក់ដូរក្បែរផ្លូវជាដើម។
- លោកក៏មានសំណូមពរមួយចំនួនទៅដល់ក្រុមហ៊ុន ពេលដំណើរការសាងសង់សូមជ្រើសរើសបុគ្គលិក កម្មករក្នុងតំបន់នេះសម្រាប់បំរើការក្នុងគម្រោង។
- ចំណែកទាក់ទងវិស័យហេដ្ឋារចនាសម្ព័ន្ធ លោកស្នើសូមក្រុមហ៊ុនជួយកសាង សាលារៀនបន្ថែម ជួសជុលផ្លូវលំ ស្ពារប្រព័ន្ធបង្ហូរទឹកស្អុយជាដើម តាមតែក្រុមហ៊ុនអាចជួយបាន។

Draft

រូបភាព៦.១៧៖ សកម្មភាពសម្ភាសន៍ផ្ទាល់ជាមួយមេភូមិទី៦ (ភូមិអូរត្រេះ)



(ប្រភព៖ Creative Green Design Co., Ltd ឆ្នាំ២០១៥)

## ៦.៤ ការពិគ្រោះយោបល់ជាមួយសហគមន៍នេសាទ

ការពិគ្រោះយោបល់ជាមួយសហគមន៍នេសាទ ត្រូវបានជ្រើសរើស ប្រជានេសាទដែលស្ថិតនៅក្នុងភូមិអុង ឃុំរាម ស្រុកព្រៃនប់ ខេត្តព្រះសីហនុ ដែលឡើងនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៦ វេលាម៉ោង២:០០ល្ងាចក្នុងភូមិអុង។ ការពិគ្រោះយោបល់នេះ ត្រូវបានធ្វើឡើងក្នុងគោលបំណងផ្សព្វផ្សាយអំពីគម្រោង និងការបង្ហាញនូវមតិយោបល់ និងសំណូមពររបស់ប្រជានេសាទទៅលើគម្រោងបង្កប់ខ្សែកាប្លិ៍នេះ។ ការបញ្ចេញមតិយោបល់ និងសំណូមពរ របស់ប្រជានេសាទមានដូចខាងក្រោម៖

- ប្រជានេសាទមានការព្រួយបារម្ភ នៅពេលក្រុមហ៊ុនបង្កប់ខ្សែកាប្លិ៍ហាមប្រជានេសាទមិនឲ្យធ្វើការនេសាទបាន។
- នៅពេលដំណើរការ ប្រព័ន្ធខ្សែកាប្លិ៍ ពួកគាត់ភ័យខ្លាចធក់ធនធានជលផល ដែលអាចធ្វើឲ្យមានការប៉ះពាល់ដល់មុខរបររបស់ពួកគាត់។
- ប្រជានេសាទស្នើរសុំ ឲ្យមានការដាក់ភ្លើងសញ្ញា ឬពោតបណ្តែតជាសញ្ញានៅតំបន់ហាម ឃាត់មិនអនុញ្ញាតឲ្យពួកគាត់ចូលនេសាទបាននៅពេលបង្កប់ខ្សែកាប្លិ៍។
- ស្នើរសុំឲ្យមានសិក្ខាសិលាបង្ហាញពីបច្ចេកវិទ្យានៃខ្សែកាប្លិ៍ អំពីផលវិជ្ជមាន និងផលអវិជ្ជមាននៃប្រព័ន្ធខ្សែកាប្លិ៍ ព្រោះពួកគាត់មានការភ័យខ្លាចធក់។

Draft

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

- ជាចុងក្រោយទោះបីជាពួកគាត់មានការព្រួយបារម្ភមួយចំនួន តែពួកគាត់នៅតែគាំទ្រចំពោះគម្រោងបង្កប់ខ្សែកាប្លិ៍នេះ ព្រោះគាត់គិតថា ការអភិវឌ្ឍន៍ឲ្យប្រទេសមានការរីកចំរើនគឺជាចំណុចល្អមួយ តែក្រុមហ៊ុនក៏ត្រូវមានវិធានការយ៉ាងណា ទប់ស្កាត់កុំឲ្យមានការប៉ះពាល់ទៅដល់ធនធានជលសមុទ្រ ព្រោះប្រជាជននៅក្នុងភូមិរបស់ពួកគាត់ភាគច្រើនពឹងផ្អែកលើមុខរបរនេះ។

រូបភាព៦.១៨៖ សកម្មភាពប្រជុំពិគ្រោះយោបល់ជាសាធារណៈ ជាមួយសហគមន៍នេសាទ



(ប្រភព៖ Creative Green Design Co., Ltd ឆ្នាំ២០១៦)

## ៦.៥ ការពិគ្រោះយោបល់ជាមួយប្រជាជន

តាមការសម្ភាសន៍ពីប្រជាជនក្នុងភូមិអូរគ្រែះចំនួន ៧១គ្រួសារ ធ្វើឡើងនៅថ្ងៃទី១២-១៤ ខែធ្នូ ឆ្នាំ ២០១៥ បានបង្ហាញឱ្យឃើញថា ៦១គ្រួសារស្មើនឹង៨៦%នៃអ្នកតបសម្ភាសន៍បានគាំទ្រលើគម្រោងសាងសង់ខ្សែកាប្លិ៍អុបទិចក្រោមបាតសមុទ្រ ចំណែកចំនួនប្រជាជនប្រមាណតែ ៧%ប៉ុណ្ណោះដែលមិនគាំទ្រទៅលើការសាងសង់ ដោយឡែកចំនួនអ្នកគ្មានយោបល់ស្មើនឹង៧%។

ប្រជាពលរដ្ឋមានការគាំទ្រលើគម្រោងនេះដោយសារពួកគាត់យល់ឃើញថា ការសាងសង់ខ្សែកាប្លិ៍អាចបង្កើនល្បឿននៃការប្រើប្រាស់អ៊ីនធឺណែតក្នុងតម្លៃទាបជាងមុន និងអាចរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេស ស្របតាមរបត់នៃការវិវឌ្ឍបច្ចេកវិទ្យាថ្មីក្នុងសម័យកាលបច្ចុប្បន្ន ចំណែកប្រជាជនមួយចំនួនមិនយល់ស្របនឹងគម្រោងសាងសង់ខ្សែកាប្លិ៍អុបទិចនេះ ដោយសារពួកគាត់បារម្ភពីបញ្ហាសុខភាពកូនចៅដែលរស់នៅក្បែរស្ថានីយ៍ អាចប៉ះពាល់ដល់ខួលក្បាលនិងស្មារតី បញ្ហាសុវត្ថិភាពនិងផលនេសាទអាចថយចុះ ដែលបណ្តាលមកពីការសាងសង់ខ្សែកាប្លិ៍កប់ក្រោមបាតសមុទ្រក្បែរតំបន់ពួកគាត់នេសាទ។

ក្រាហ្វិក៦.១៖ ការគាំទ្រ និងមិនគាំទ្រទៅលើគម្រោងសាងសង់ខ្សែកាប្លិ៍អុបទិច




(ប្រភព៖ Creative Green Design Co., Ltd ឆ្នាំ២០១៥)

រូបភាព ៦.១៩៖ សកម្មភាពក្រុមការងារធ្វើការសម្ភាសប្រជាជនក្នុងភូមិអូរត្រេះ



(ប្រភព៖ Creative Green Design Co., Ltd ឆ្នាំ២០១៥)

## ៦.៦ សង្ខេបលទ្ធផលនៃការពិគ្រោះយោបល់ជាសាធារណៈ

តាមរយៈការប្រជុំពិភាក្សាពិគ្រោះយោបល់នៅសាលាព្រះសីហនុ ដែលមាន **ឯកឧត្តម ឈិន សេងខួន** អភិបាលរងខេត្តព្រះសីហនុជាគណៈអធិបតី និងមានក្រុមហ៊ុនទីប្រឹក្សា **គ្រីអេធីវ ហ្គ្រីន ឌីហ្សាញ** ជាអ្នកធ្វើបទបង្ហាញ ព្រមទាំងមានមន្ទីរ និងស្ថាប័នដែលពាក់ជាច្រើនបានមកផ្តល់យោបល់ និងអនុសាសន៍ផ្សេងៗដែលទាក់ទងនឹងគម្រោងបង្កប់ខ្សែកាប្លិ៍ក្រោមបាតសមុទ្រកម្ពុជា របស់ក្រុមហ៊ុន TELCOTECH LTD បានបង្ហាញឲ្យឃើញថាការរៀបចំរបាយការណ៍ និងការធ្វើបទបង្ហាញរបស់ក្រុមហ៊ុនទីប្រឹក្សាបានល្អប្រសើរ ប៉ុន្តែក៏មានចំណុចខ្វះខាតមួយចំនួនដែលត្រូវបំពេញបន្ថែមដូចជា៖

- ក្រុមហ៊ុនត្រូវបង្ហាញអោយច្បាស់ពីគន្លងកប់ខ្សែកាប្លិ៍ទាំងក្នុងទឹក និងលើគោកដែលមាននិយាមការច្បាស់លាស់ ដើម្បីតំកល់ប្លង់នៅសាលាខេត្ត។

#322P, St.271Z, Sk.Terk Tla, Khan Resey Keo, Phnom Penh.
Tel: (855-11) 845 695 / 097 204 6789
E-mail: saphoeuntous09@yahoo.com / www.CREATIVE09.com

- ការអូសខ្សែកាប្លិ៍គួរបង្វែរទៅតាមព្រែកវិញ កុំអូសកាត់សួនច្បារ ឆ្នេរកំសាន្ត កន្លែងងូតទឹករបស់ប្រជាពលរដ្ឋ។
- ការសិក្សាបាតសមុទ្រគួរមាន Video clip ទុកមើល និងមានឯកសារសម្រាប់ជាភ័ស្តុតាង។
- ចំពោះក្រុមមុជទឹកស្រាវជ្រាវបាតសមុទ្រ មានការទទួលស្គាល់ពីស្ថាប័នណា ឈ្មោះអ្វី។
- ក្រុមមុជទឹកត្រូវតែមានការពិគ្រោះយោបល់ជាមួយអង្គការ ឬភ្នាក់ងារដែលកំពុងប្រតិបត្តិការក្នុងខេត្តព្រះសីហនុ ទាក់ទងនឹងការអភិរក្សធនធានបាតសមុទ្រ ដោយសារមានតែពួកគាត់ដឹងពីវិសាលភាពនៃធនធានបាតសមុទ្រ ផ្នែកណាខ្លាំង និងផ្នែកណាកំពុងឈានទៅរកមហន្តរាយ និងការធ្វើអោយមានការកកើតឡើងវិញ។
- ការតបណ្តាញខ្សែកាប្លិ៍ គួរតែធ្វើនៅរដូវដែលមានភ្ញៀវទេសចរតិច ដើម្បីសុវត្ថិភាពការងារ។
- ត្រូវបង្ហាញឲ្យបានច្បាស់ថាតើការអូសខ្សែកាប្លិ៍នេះមានផលប្រយោជន៍អ្វីខ្លះដល់ ប្រទេសជាតិ និងប្រជាពលរដ្ឋ? ត្រូវបកស្រាយពីផលប្រយោជន៍ឱ្យបានច្បាស់ និងត្រូវមានវិធានការកាត់បន្ថយផលប៉ះពាល់បែបណា ដើម្បីឱ្យប្រជាជនក្នុងតំបន់មានទំនុកចិត្ត។
- ក្រុមហ៊ុនគួរតែមានការផ្សព្វផ្សាយលទ្ធផលសិក្សាជាសាធារណៈឱ្យបានដឹង។

សម្រាប់ការពិគ្រោះយោបល់ជាមួយអាជ្ញាធរមូលដ្ឋាន (មេភូមិ៦) គឺគាត់មានការគាំទ្រចំពោះគម្រោងអភិវឌ្ឍន៍នេះ ព្រោះគាត់សង្ឃឹមថា គម្រោងនេះនឹងអាចស្រូបកំលាំងពលកម្មបានច្រើន ផ្តល់នូវបច្ចេកវិទ្យាទំនើប និងមានតម្លៃថោកជាងមុន ដែលអាចលើកកម្ពស់ការរស់នៅរបស់ប្រជាជន។ យ៉ាងណាមិញសម្រាប់ប្រជាពលរដ្ឋដែលរស់នៅក្បែរតំបន់ស្ថានីយ៍ខ្សែកាប្លិ៍គឺ មានការគាំទ្រច្រើនចំពោះគម្រោងអភិវឌ្ឍន៍នេះដែលមានរហូតដល់ ៨៦% នៃប្រជាជនដែលបានសម្ភាសន៍។

ចំណែកការពិគ្រោះយោបល់ជាមួយ សហគមន៍នេសាទ ឃើញថាប្រជានេសាទមានការព្រួយបារម្ភ ភ័យខ្លាចខ្សែកាប្លិ៍ធក់ ដែលធ្វើឲ្យមានការថយចុះនូវធនធានជលផល ដែលជាប្រភពសំខាន់នៃមុខរបររបស់គាត់។ តែទោះជាយ៉ាងណា ក៏ពួកគាត់គាំទ្រលើគម្រោងបង្កប់ខ្សែកាប្លិ៍នេះដែរព្រោះគាត់គិតថា ការនាំចូលនូវបច្ចេកវិទ្យាទំនើប អាចធ្វើឲ្យមានការរីកចំរើននូវការអភិវឌ្ឍន៍ ធ្វើឲ្យជីវិតរស់នៅរបស់ប្រជាជនងាយស្រួលជាងមុន។